**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ១៣៨៨ គ.ជ.ប

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)** សូមជូនដំណឹងជាសាធារណៈដល់គណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ ហើយដែលមានបំណងសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ដែលនឹងប្រព្រឹត្តទៅនៅ**ថ្ងៃទី១៤ ខែមករា ឆ្នាំ ២០១៨** ឱ្យបានជ្រាបថា ៖

- ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ត្រូវធ្វើនៅ គ.ជ.ប។
- គណបក្សនយោបាយ ដែលមានបំណងឈរឈ្មោះបោះឆ្នោត ត្រូវមកយកគំរូពាក្យសុំ ចាប់ពី**ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧** ឬអាចទាញយកពីគេហទំព័រ គ.ជ.ប (www.necelect.org.kh) និងដាក់ពាក្យសុំចុះបញ្ជីឈរឈ្មោះបោះឆ្នោត នៅទីស្តីការ គ.ជ.ប (ការិយាល័យកិច្ចការគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ បន្ទប់ A24)។
- កាលបរិច្ឆេទ និងពេលវេលាទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ចាប់ផ្តើមពី**ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧** ដល់**ថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១៧** នៅរៀងរាល់ម៉ោងធ្វើការ។
- ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ត្រូវមានភ្ជាប់មកជាមួយនូវ ៖
  - ឯកសារពាក់ព័ន្ធដូចមានក្នុងទម្រង់បែបបទលេខ ១០០៨។
  - បង្កាន់ដៃបង់ប្រាក់តម្កល់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន)រៀល។ ប្រាក់តម្កល់នេះ ត្រូវបង់នៅអគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងគណនីប្រាក់តម្កល់របស់ គ.ជ.ប ដែលមានគណនីលេខ ៤៧០៦២.១.២.៣០។

គ.ជ.ប សង្ឃឹមទុកជាមុនថា គ្រប់គណបក្សនយោបាយ ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៧

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ស៊ិក ប៊ុនហុក